# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៤០/២២ ក.ប/ស.ជ.ណ.ប.ស.ស

## សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ថ្នាក់ដឹកនាំនៅតាមក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបានជ្រាបថា កន្លងមកក្រសួងបានសង្កេតឃើញនៅតាមបណ្តាក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ កំពុងប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាដែលមិនមានការទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ ហើយមន្ត្រីជាប់កិច្ចសន្យាទាំងនោះពុំទាន់ទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គមពីបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ស្របតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមនៅឡើយ។ ក្នុងន័យនេះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ថ្នាក់ដឹកនាំនៅតាមក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកំពុងប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាដូចបានរៀបរាប់ខាងលើ ត្រូវបញ្ជូនមន្ត្រីជាប់កិច្ចសន្យាទាំងនោះមកចុះបញ្ជី និងបង់ភាគទានមក ប.ស.ស. ដើម្បីឱ្យពួកគាត់ទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គមពីបេឡាជាតិសន្តិសុខសង្គមស្របតាមបទប្បញ្ញត្តិជាធរមាន។

ចំពោះបែបបទ និងនីតិវិធីលម្អិត នៃការចុះបញ្ជីនិងបង់ភាគទាន សូម ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើការទំនាក់ទំនងទៅតាមបណ្តាសាខា ប.ស.ស. រាជធានី ខេត្ត/ខណ្ឌ ឬអាចទំនាក់ទំនងតាមរយៈ Hotline ១២៨៦ ឬទូរស័ព្ទលេខ ០២៣ ២៦០ ០០១/០២៣ ៨៨១ ០១៥។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំនៅតាមក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងចូលរួមសហការអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះប្រកបដោយស្មារតីទទួលខុសត្រូវ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០២២
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលថ្នាក់ក្រោមជាតិ
  *" ដើម្បីជូនជ្រាប ផ្សព្វផ្សាយ និងសហការអនុវត្ត "*
- គ្រប់មន្ទីការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់សាខា ប.ស.ស. រាជធានី ខេត្ត/ខណ្ឌ
  "ដើម្បីអនុវត្ត"